# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៧៦ ព្រទ.កយ-២០០៤

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## <u>ជម្រាបមក</u>

### លោក លោកស្រីប្រធានតុលាការខេត្ត-ក្រុង
### លោកប្រធានតុលាការយោធា

**<u>កម្មវត្ថុ:</u>** អំពីសំណុំឯកសារបន្ធូរបន្ថយ និងលើកលែងទោសឱ្យទណ្ឌិតតាមសំណើរបស់តុលាការ ។

**<u>យោង:</u>** លិខិតលេខ ១២៩១ ព្រទ.កយ ២០០២ ចុះថ្ងៃទី២៧-១២-២០០៦ របស់ក្រសួងយុត្តិធម៌ ។

តតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបអស់លោក-លោកស្រីប្រធានជ្រាបថា រៀងរាល់ឱកាសបុណ្យចូលឆ្នាំជាតិ បុណ្យពិសាខបូជា និងបុណ្យចម្រើនព្រះជន្ម-តាំងតុ-អកអំបុកសំពះព្រះខែនិងក្នុងកាលៈទេសៈផ្សេងទៀត (ដូចជាការសុំសេរីការដោយមានលក្ខខ័ណ្ឌ និងការដោះលែងទណ្ឌិតដែលកើតជម្ងឺអេដស៍ធ្ងន់ធ្ងរ)ក្រសួងបានពិនិត្យឃើញថា សំណុំឯកសារស្នើសុំបន្ធូរបន្ថយ និងលើកលែងទោសឲ្យល្អិតមួយចំនួន ពុំមានលក្ខណៈគ្រប់គ្រាន់ដែលអាចឱ្យក្រសួងចាត់ការជូនតាមសំណើបានឡើយ ។

ដើម្បីឱ្យក្រសួងមានមូលដ្ឋានពិនិត្យចាត់ការ នូវសំណើស្តីពីការសុំបន្ធូរបន្ថយទោសនិងលើកលែងទោសដល់ទណ្ឌិតបាន ក្រសួងសូមធ្វើការណែនាំបន្ថែមដូចខាងក្រោម ៖

១-សាលក្រម ឬសាលដីកាព្រហ្មទណ្ឌ ត្រូវមានកំណត់អំពីកាលបរិច្ឆេទនៃការចាប់ខ្លួន ឬឃុំខ្លួន និងមានចំណារអំពីអានុភាពអនុវត្ត នៃអំណាចសាលក្រម ឬសាលដីកាព្រហ្មទណ្ឌស្ថាពរ (ថ្ងៃចូលស្ថាពរ) ។

២-ក្នុងករណីដែលសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ឬរបស់តុលាការកំពូលសម្រេចតម្កល់សេចក្តីសម្រេច ឬចំណុចណាមួយនៃសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ប៉ុន្តែក្នុងសាលដីកានោះមិនឃើញមានស្រង់សេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមទេ ត្រូវភ្ជាប់មកជាមួយនូវសាលក្រមរបស់ថ្នាក់ក្រោមនោះផង ។

៣-សម្រង់ជំនុំជម្រះ ដែលអយ្យការ-តុលាការបានផ្តល់ជូនទៅមន្ទីរឃុំឃាំងឬពន្ធនាគារមិនមានតម្លៃជាមូលដ្ឋានសម្រាប់ធ្វើការស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសបានទេ ។ វាគ្រាន់តែជាលិខិតបង្អែកបណ្តោះអាសន្នសម្រាប់នាំខ្លួនទណ្ឌិតទៅដាក់ឃុំឃាំងក្នុងពន្ធនាគារប៉ុណ្ណោះ ។ ដូច្នេះ ត្រូវតែមានសាលក្រម ឬ សាលដីកាភ្ជាប់មកជាមួយ ។

៤-ចំពោះទណ្ឌិតដែលត្រូវផ្តន្ទាទោសប្រហារជីវិត តាមអំណាចសាលក្រមព្រហ្មទណ្ឌនាទសវត្ស១៩៨០ ហើយត្រូវបានអនុគ្រោះទោសមកជាទោសពន្ធនាគារអស់មួយជីវិត ឬទោសពន្ធនាគារមានកំណត់វិញ តម្រូវឱ្យមានលិខិតគតិយុត្ត (ជាក្រឹត្យ ជាសេចក្តីសម្រេចពីប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល) ដែលបញ្ជាក់អំពីការអនុគ្រោះទោសនោះភ្ជាប់មកជាមួយ បើពុំដូច្នោះទេ ក្រសួងមិនអាចចាត់ការតាមសំណើបានឡើយ ។

៥-រាល់ឯកសារថតចម្លង (រួមទាំងសម្រង់ និងសេចក្តីចម្លងសាលក្រម ឬសាលដីកាផង) ត្រូវមានសេចក្តីបញ្ជាក់ (ប្រថាប់ត្រាថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម) ទើបមានសុពលភាពប្រើប្រាស់ជាផ្លូវការត្រឹមត្រូវតាមច្បាប់ទៅតាមករណីនីមួយៗដែលត្រូវប្រើ ។

៦-អយ្យការ តុលាការ គប្បីពិនិត្យរាល់ឯកសារស្នើសុំបន្ធូរបន្ថយ និងលើកលែងទោសដល់ទណ្ឌិតឱ្យបានហ្មត់ចត់ និងមានទំនាក់ទំនងជិតស្និទ្ធជាមួយស្ថាប័នពន្ធនាគារ ឬមន្ទីរអប់រំកែប្រែ ដើម្បីផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក អំពីកង្វះខាតនៃសំណុំឯកសារ អំពីលក្ខខ័ណ្ឌនៃការសុំបន្ធូរបន្ថយ និងលើកលែងទោសដល់ទណ្ឌិតដែលមានចែងក្នុងក្រឹត្យលេខ២៨ ក្រ ចុះថ្ងៃទី២០-០៦-១៩៨៨ និងអំពីពេលវេលាសមស្រប ដែលត្រូវបញ្ជូនសំណើសុំបន្ធូរបន្ថយ និងលើកលែងទោសទណ្ឌិតដូចបានណែនាំក្នុងលិខិតលេខ ១២៩១ព្រម.កយ/២០០២ ចុះថ្ងៃ២៧-១២-២០០២ របស់ក្រសួងយុត្តិធម៌កន្លងមក ។

ដូច្នេះដើម្បីធានា និងលើកស្ទួយការគោរពសិទ្ធិមនុស្ស ការចូលរួមក្នុងវិស័យនយោបាយកែទម្រង់ប្រព័ន្ធច្បាប់ និងយុត្តិធម៌ របស់រាជរដ្ឋាភិបាល ក្រសួងសូមលោក លោកស្រីប្រធានយកចិត្តទុកដាក់អនុវត្តសេចក្តីណែនាំនេះឱ្យបានល្អប្រសើ និងមានប្រសិទ្ធភាពខ្ពស់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៤

**រដ្ឋមន្ត្រី**

**ឆាង ស៊ីផុខ**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-តុលាការកំពូល
-មហារយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍
-មហាអយ្យការអមសាលាឧទ្ធរណ៍
-អយ្យការអមតុលាការខេត្ត-ក្រុង
-អយ្យការយោធា
-ដើម្បីជូនជ្រាប
-ឯកសារ - កាលប្បវត្តិ